ចូល
លេខ ១៣៧២
ថ្ងៃទី ២/២ ឆ្នាំ ២០២២ ម៉ោង ១០:៣០
បញ្ជូនទៅ T. ...

# ព្រះរាជក្រម

នស/រកម/០១២២/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

# ស្ដីពី

# វិសោធនកម្មច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម
# និងបញ្ជីពាណិជ្ជកម្ម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រាមួយ .-**

មាត្រា១១ថ្មី មាត្រា១៤ថ្មី មាត្រា១៧ថ្មី និងមាត្រា២៦ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងមាត្រា៤៧នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១១ .- ថ្មី(ពីរ)**

ក្រសួងពាណិជ្ជកម្មត្រូវបញ្ជូនបញ្ជីពាណិជ្ជកម្មនិងរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មមួយច្បាប់ទៅតុលាការពាណិជ្ជកម្ម ដើម្បីជាឯកសារសម្រាប់យុត្តាធិការពាណិជ្ជកម្ម។

**មាត្រា១៤ .- ថ្មី(ពីរ)**

យ៉ាងតិចបំផុត១៥(ដប់ប្រាំ)ថ្ងៃមុនពេលចាប់ផ្តើមធ្វើពាណិជ្ជកម្មរបស់ខ្លួន ពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅកន្លែងដែលខ្លួនធ្វើអាជីវកម្ម។

ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មមាននៅតាមមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ឬនៅទីកន្លែងផ្សេងទៀតតាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម។

ពាណិជ្ជករត្រូវប្រគល់ទៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍មួយ ដោយធ្វើជាពីរច្បាប់មានចុះហត្ថលេខាឬស្នាមមេដៃរបស់សាមីខ្លួន។

ប្រតិវេទន៍នេះត្រូវសរសេរលើលិខិតគំរូមួយដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មបានផ្តល់ឱ្យ។

ប្រតិវេទន៍ត្រូវចែងអំពី៖

១-នាមត្រកូលនិងនាមខ្លួនរបស់ពាណិជ្ជករនិងលេខនៃលិខិតអត្តសញ្ញាណរបស់ខ្លួន។

២-នាមប្រើប្រាស់ក្នុងពាណិជ្ជកម្មឬហេស្សនាម។

៣-ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើត អាសយដ្ឋានផ្ទាល់ខ្លួន លេខទូរស័ព្ទទំនាក់ទំនង និង/ឬអាសយដ្ឋានទំនាក់ទំនងអេឡិចត្រូនិក។

៤-សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀតត្រូវបញ្ជាក់អំពីបែបបទនិងថ្ងៃ-ខែ-ឆ្នាំ ដែលបានទទួលសញ្ជាតិនេះ។

៥-កម្មវត្ថុអាជីវកម្ម អនុលោមតាមចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា ដែលបានដាក់ឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

៦-ទីកន្លែងធ្វើអាជីវកម្មនិងអាសយដ្ឋាន គ្រឹះស្ថានឬសាខានៃមូលនិធិពាណិជ្ជកម្មដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា។

៧-ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាន(ប្រសិនបើមាន)។

៨-លិខិតអត្តសញ្ញាណរបស់អ្នកតំណាងពេញសិទ្ធិដែលទទួលរ៉ាប់រងក្នុងការសុំចុះបញ្ជីពាណិជ្ជកម្ម។

៩-គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំបានធ្វើអាជីវកម្មពីមុនឬគ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំកំពុងធ្វើពាណិជ្ជកម្មនៅក្នុងរង្វង់សមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។

១០-សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១១-ក្នុងករណីចាំបាច់ លិខិតអនុញ្ញាតឱ្យប្រកបមុខរបរចំពោះមុខរបរណាឬចំពោះកម្មវត្ថុអាជីវកម្មណាដែលតម្រូវឱ្យមានសេចក្តីអនុញ្ញាត។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ចូលក្នុងបញ្ជីពាណិជ្ជកម្មដោយប្រគល់ប្រតិវេទន៍នេះមួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ ជូនដល់អ្នកស្នើសុំចុះឈ្មោះដោយបញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលបញ្ជីរួចហើយ"។

**មាត្រា១៧ .– ថ្មី(ពីរ)**

គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើតនិងថិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។

ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនេះត្រូវធ្វើឡើងដោយបណ្ណាធិការឬអភិបាលនៃក្រុមហ៊ុននៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និង១៥(ដប់ប្រាំ)ថ្ងៃមុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម។

អ្នកស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវផ្តល់ដល់ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំ ព្រមទាំងតម្កល់លក្ខន្តិកៈក្រុមហ៊ុនផង។

ប្រតិវេទន៍ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជូននោះត្រូវចែងអំពី៖

១-នាមត្រកូលនិងនាមខ្លួនរបស់សមាជិកក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំនិងទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ លេខទូរស័ព្ទទំនាក់ទំនង និង/ឬអាសយដ្ឋានទំនាក់ទំនងអេឡិចត្រូនិក។

២-ផ្លាកសញ្ញារបស់ក្រុមហ៊ុន(ប្រសិនបើមាន)។

៣-កម្មវត្ថុអាជីវកម្មអនុលោមតាមចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជាដែលបានដាក់ឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

៤-ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើម សាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា។

៥-នាមត្រកូលនិងនាមខ្លួននៃសមាជិកឬតតិយជនដែលមានការអនុញ្ញាតឱ្យគ្រប់គ្រងចាត់ចែង ចុះចាត់ចែង និងចុះហត្ថលេខា ជំនួសមុខក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនេះ។

៦-ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ឬវត្ថុមានតម្លៃ ដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុនដោយភាគហ៊ុន។

៧-ថ្ងៃ-ខែ-ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើមនិងបញ្ចប់(ប្រសិនបើមាន)។

៨-ទ្រង់ទ្រាយក្រុមហ៊ុន។

៩-សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថាគ្មានទោសពៃរ៍ក្នុងរឿងព្រហ្មទណ្ឌឬការបាត់បង់សិទ្ធិ ឬការហាមឃាត់សិទ្ធិក្នុងកិច្ចការពាណិជ្ជកម្មឡើយ សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់ជាក្រោយ។

**មាត្រា២៦ ... ថ្មី(ពីរ)**

យោងតាមប្រតិវេទន៍ជាលាយលក្ខណ៍អក្សរនិងរាល់ឯកសារតម្កល់ទុក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីនិងភ្ជាប់ជាមួយនូវសម្រង់ដែលមានចុះអត្តលេខសម្គាល់ក្នុងបញ្ជីពាណិជ្ជកម្ម ហើយដែលអត្តលេខនេះមានតែមួយគត់សម្រាប់ការធ្វើសកម្មភាពពាណិជ្ជកម្មផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ វិញ្ញាបនបត្រនេះស្ថិតក្នុងលក្ខណៈជាបណ្តោះអាសន្នក្នុងថិរវេលា១(មួយ)ខែ គិតចាប់ពីកាលបរិច្ឆេទដែលបានផ្តល់ជូន។ ក្នុងថិរវេលានេះ ប្រសិនបើរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំឬផ្តល់ព័ត៌មានមិនពិតដោយទុច្ចរិតឬមានបណ្តឹងតវ៉ាដែលមានអានុភាពតាមច្បាប់ជាធរមាន ក្រោយពេលចុះបញ្ជី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ពាណិជ្ជកម្ម មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មអាចបដិសេធការចុះបញ្ជីនិងអាចលុបចោលអត្តលេខសម្គាល់ដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្មនោះ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មដែលផ្តល់វិញ្ញាបនបត្រក្លែងបន្លំដោយដឹងហេតុផលសព្វគ្រប់ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**មាត្រា៤៧ .‒ ថ្មី**

រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្ម មានកាតព្វកិច្ចអនុវត្តវិធានគណនេយ្យនិងសវនកម្មដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌខាងលើ ត្រូវទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រាពីរ .‒**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ១៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២២

នស/រកម.០១២២.០០៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**